សារព័ត៌មាន
# ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ
ឆ្នាំទី ០២ លេខ ២៤៤ ចេញផ្សាយថ្ងៃ អាទិត្យ-អង្គារ ទី ១៤-១៦ ខែ កញ្ញា ឆ្នាំ ២០០៨

## អោយសៀមបោកអស់ចិត្តហើយទើបរដ្ឋាភិបាល ហ៊ុន សែន ត្អាក់កំណើតចង់ប្តឹងទៅ អ.ស.ប



នាយករដ្ឋមន្ត្រី ហ៊ុន សែន



អតីតនាយករដ្ឋមន្ត្រីសៀម សាម៉ាក់ ស៊ុនដារ៉ាវេត

ដោយ : គ.អរពិន្ទ

បញ្ហានៃការរំលោភឈ្លានពានកាន់កាប់ដីខ្មែរច្រើនកន្លែងតាមបណ្តោយព្រំដែនដោយពួកទាហានសៀមតាំងពីពាក់កណ្តាលខែកក្កដាមក ហើយសៀមបានអូសទាញរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ឱ្យចរចា

តទៅទំព័រ៤ ស

## ច័ន្ទ សារុន គួរតែផ្លាស់ប្តូរការប្រឡងដ៏ចម្លែកនៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទនេះចោលទៅ



ទិដ្ឋភាពនៃការកាប់ឈើខុសច្បាប់គាងដោយកម្លាំងប្រដាប់អាវុធ



រដ្ឋមន្ត្រី ច័ន្ទ សារុន

ដោយ : ជ.ឧត្តម

មានសេចក្តីរាយការណ៍ព័ត៌មានមួយបានឱ្យយើងដឹងថា ការប្រឡងប្តូរក្របខ័ណ្ឌមន្ត្រីរាជការនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទហាក់ដូចជាចម្លែកខុសគេខុសឯងតែម្តង ព្រោះនៅពេលដែលមានការ

តទៅទំព័រ២ ១

## ជា ស៊ីម មិនលាលែងពីសមាជិកសភា

ដោយ : សច្ចៈ

ប្រធាន គណបក្សប្រជាជនកម្ពុជាលោក*ជា ស៊ីម* នៅមិនទាន់លាលែង ពីសមាជិកសភាមណ្ឌលភ្នំពេញទេបើទោះបីជាគាត់ ជាប្រធានព្រឹទ្ធសភា ប្រធានគណបក្សប្រជាជន និងជាប្រមុខរដ្ឋស្តីទីម្តងម្កាល នៅ

តទៅទំព័រ៣ គ



លោក ជា ស៊ីម ប្រធានគណបក្សប្រជាជនដែលមិនសុខមានអំណាច

## ក្រសួងការពារជាតិប្រកាសជ្រើសរើសកងទ័ព



លោក យឹម សុវណ្ណ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញ



លោក ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិ





ទាហាននៅក្នុងជួរកងយោធពលខេមរភូមិន្ទរបស់ប្រទេសកម្ពុជា ត្រូវបានគេសង្ស័យថាមានចំនួនតួលេខច្រើនជាងចំនួនមនុស្ស

ដោយ : ស្សាវីរិយ៍

ឧត្តមសេនីយ៍ឯក*ផាន់ ងួន* មន្ត្រីយោធា នៃក្រសួងការពារជាតិបានប្រកាសជូនដំណឹងដល់និស្សិត និងយុវជន ដែលមានបំណងចូលក្នុងជួរកងទ័ពដើម្បីបំរើប្រទេសជាតិ ។ ការជ្រើសរើស ដែលប្រកាសនៅតាមស្ថានីយ៍ទូរទស្សន៍ កងយោធពលខេមរភូមិន្ទ កាលពីព្រឹកម្សិលមិញ ស្របពេលដែលទាហាន

តទៅទំព័រ៤ ម

## សុន ឆ័យ មានតម្រោងនាំឪពុក ទឹម សាខន ទៅសួរសុខទុក្ខលោកដោយផ្ទាល់ដល់ស្រុកយួន



លោក សុន ឆ័យ អ្នកនាំពាក្យគណបក្សសមរង្ស៊ី



លោកតា ទឹម ចឿម ឪពុកដ៏ចាស់ជរារបស់លោក ទឹម សាខន

ដោយ : ទិសាល

ទោះបីជាមន្ត្រីស្ថានទូតយួនប្រចាំស្រុកខ្មែរមិនទាន់មានការឆ្លើយតបទៅនឹងសំណើរបស់លោក *សុន ឆ័យ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីយ៉ាងណាក៏ដោយ ក៏លោកមានគម្រោងធ្វើដំណើរជាឯកជនជាមួយក្រុមគ្រួសារអតីតព្រះសង្ឃ *ទឹម សាខន* នៅដើមខែតុលាឆ្នាំ២០០៨ដើម្បីទៅសួរសុខទុក្ខ

តទៅទំព័រ២ ន

## ទ្រង់ រណឫទ្ធិ អាចបានតំណែងក្នុងរដ្ឋាភិបាល គ្រាន់នឹងលក់ខ្លួនបើសព្វព្រះទ័យលន់តួ ញឹក ប៊ុនឆៃ



ទ្រង់ រណឫទ្ធិ និង ញឹក ប៊ុនឆៃ កាលនៅផ្អែមល្ហែមជាមួយគ្នា



លោក មុត ចន្ថា



លោក សៅ រ៉ានី

ដោយ : រតនៈ

ព្រះរាជបុត្រលោភលន់ និងល្មោភតណ្ហា ព្រះនាម*នរោត្តម រណឫទ្ធិ* នៅតែមិនអាចយាងត្រឡប់ចូលស្រុកបាន ដោយសារចរិតលោភលន់និងចង់បានដោយមិនខ្មាសអៀន ហួសប្រមាណ ខណៈពេលដែលគណបក្សនរោត្តម រណឫទ្ធិ របស់ព្រះអង្គ ធ្លាក់ប្រជាប្រិយភាពយ៉ាងរខេករខាកទទួលបានកៅ

តទៅទំព័រ២ ខ

## ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក មកដល់កម្ពុជាថ្ងៃនេះហើយ



លោក John Negroponte

ដោយ : គ.រដ្ឋា

លោក John Negroponte ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកនឹងធ្វើដំណើរពីទីក្រុងហូជីមិញប្រទេសយួនមកដល់ប្រទេសកម្ពុជានៅថ្ងៃអាទិត្យទី១៤ខែកញ្ញានេះហើយសម្រាប់ការបំពេញទស្សនកិច្ចជាផ្លូវការ

តទៅទំព័រ៣ ឃ

## ដំណឹងពិសេសដ៏អស្ចារ្យ

ពីលោកគ្រូ **ហោ លីម** ព្យាបាលតាមរបៀបម៉ាស្សា លាប រឹត ស្ទំ ថ្នាំបុរាណខ្មែរ ធូរស្បើយក្នុង រយៈពេល **១ម៉ោង (មិនធូរស្បើយមិនគិតលុយ)** នូវជំងឺមនុស្សចាស់ ចុកចាប់ក្នុងរាងកាយ, ឈឺក្បាលជាយូរឆ្នាំក្តី, ឈឺជង្គង់, ឈឺសន្លាក់ដៃ សន្លាក់ជើង, រោយឆ្អឹងខ្នង, តឹងច្រមុះ, តឹងទ្រូង, ថប់ដង្ហើម, ញ័រទ្រូង, ទល់ឆ្អល់ក្នុងពោះ, ពិបាកបត់ជើងតូចធំ, ជាពិសេសជំងឺ១០០មុខក្នុង រាងកាយ ។ល។ **ផ្នែកសម្រស់ :** សង្ហាពោះក្រាស់ ជាំមុខ គ្មានដោះ ឬដោះស្បើត ព្យាបាល យ៉ាងស័ក្តិសិទ្ធិ។

- មានបន្ទប់បុរស ស្ត្រី ដាច់ដោយឡែកពីគ្នា
- មានលក់ថ្នាំសម្រាប់ព្យាបាលដោយខ្លួនឯង

ទីតាំងផ្ទះលេខ០៧៧ **ហោ លីម ថៃសម្ផស្ស** ច្រកចូលផ្លូវមានដំបូល ជាប់របងស្អាតចាស់ សង្កាត់ស្រះចក ខណ្ឌដូនពេញ

ទូរស័ព្ទទំនាក់ទំនង : 012 363 331, 016 719 616,

*បរិយាយថ្ងៃនេះ*

## បើមិនការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិមែន រាស្ត្រខ្មែរចាំតែវេទនាទៅ

ដោយ : ហង្ស ច្រាផ្កា

នៅពេលនេះរដ្ឋាភិបាលថ្មីអាណត្តិទី៤នៅមិនទាន់កើតមាននៅឡើយទេ ហើយដែលអ្នកទន្ទឹងយ៉ាងអន្ទះសារចង់ឱ្យរដ្ឋាភិបាលនេះកើតឡើងឆាប់រហ័សបំផុតដើម្បីឱ្យខ្លួនអាចឡើងធ្វើជានាយករដ្ឋមន្ត្រីថ្មី និងមានពេលដើរឃោសនាលើកមុខខ្លួនឯងនៅតាមទីកន្លែងនានានោះ ប្រជារាស្ត្រខ្មែរក៏កំពុងមានកង្វល់បារម្ភចំពោះបញ្ហាធំមួយទៀត។ នោះគឺបញ្ហានៃ

តទៅទំព័រ៤ ក

Tel: 012 850 690 / 017 360 678 , Fax: 023 987 411

តមកពីទំព័រ១ ខ

ប្រឡងអស់រាប់ខែរាប់អាណត្តិ ហើយបែរជាពុំមានការប្រកាសលទ្ធផលទាល់តែសោះ។

យោងតាមលិខិតមិត្តអ្នកអានមួយច្បាប់ដែលគេបានដាក់ចំណងជើងធំៗថា "ការប្រឡងដ៏ចម្លែកនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ " ដែលការិយាល័យនិពន្ធយើងទើបនឹងទទួលបានកាលពីថ្ងៃសៅរ៍ម្សិលមិញនេះ គឺលិខិតនោះបានសម្តែងនូវការខកចិត្តយ៉ាងខ្លាំង ព្រោះបើគិតពីថ្ងៃទី២៧ខែមេសា ឆ្នាំ២០០៨ រហូតមកដល់ពេលនេះ វាមានរយៈពេលជាង៤ខែហើយដែលការប្រឡងប្តូរក្របខ័ណ្ឌមន្ត្រីរាជការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតែមិនព្រមប្រកាសលទ្ធផលឱ្យដឹងទៀត។

លិខិតដដែលនេះបានបន្តទៀតថា "តែបើគិតជាអាណត្តិវិញ គឺអស់រយៈពេល២អាណត្តិកន្លងមកហើយដែលការប្រឡងប្តូរក្របខ័ណ្ឌនោះមិនត្រូវបានក្រសួងប្រកាសលទ្ធផលឱ្យមន្ត្រីរាជការដឹងឡើយ ។ ហើយបើគង់តែមិនប្រកាសលទ្ធផលដដែល តើក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទចាំបាច់អ្វីនឹងបង្កើតឱ្យមានការប្រឡងប្តូរក្របខ័ណ្ឌមន្ត្រីរាជការនោះ " ?

លិខិតបានអត្ថាធិប្បាយតាមរបៀបឈឺចិត្តឆ្អិតឆ្អៅថា មន្ត្រីរាជការតូចតាចដែលពឹងផ្អែកលើប្រាក់ខែដ៏តិចតួចស្តួចស្តើងរបស់ខ្លួនបានព្យាយាមទន្ទឹងរង់ចាំដំណឹងនៃការប្រកាសលទ្ធផលនេះយ៉ាងអន្ទះសារបំផុត។

មិនតែប៉ុណ្ណោះគេបានឱ្យដឹងទៀតថា "ក្នុងអំឡុងពេលរង់ចាំនេះ គឺមន្ត្រីរាជការតូចតាចបានទទួលព័ត៌មានលួចល្បៀងមកថា ការធ្វើកំណែប្រឡងនោះបានចង់សព្វគ្រប់តាំងពីយូរយារណាស់មកហើយៗការប្រកាសលទ្ធផល និងការជ្រើសរើសមន្ត្រីដែលមានវាសនាបានប្តូរក្របខ័ណ្ឌនោះ ក៏ស្ថិតនៅក្នុងដៃលោករដ្ឋមន្ត្រី ច័ន្ទ សារុន តាំងពីយូរណាស់មកហើយដែរ "។

លិខិតបានបន្តទៀតថាការមិនព្រមប្រកាសលទ្ធផលជាផ្លូវការនេះ ត្រូវបានប្រភពខ្លះនិយាយតាមរបៀបមន្ទិលសង្ស័យចំពោះចិត្តគំនិតដ៏អាក្រក់របស់លោក ច័ន្ទ សារុន ថា "លទ្ធផលដែលទទួលបាននោះមិនជាទីពេញចិត្តរបស់លោករដ្ឋមន្ត្រី។

លិខិតដដែលនេះបានសង្កត់ធ្ងន់ថា "អ្នកដែលជាប់ភាគច្រើនជាមន្ត្រីរាជការតូចតាចមានសមត្ថភាពពេញលេញតែលោករដ្ឋមន្ត្រីដ៏មហិមាចង់ឱ្យលទ្ធផលនោះធ្លាក់ទៅលើបុគ្គលណាដែលមានតួនាទីធំៗស្រាប់ទៅវិញ" ។តើជាការពិតដែរឬទេលោករដ្ឋមន្ត្រី ច័ន្ទ សារុន ?

យោងតាមហេតុផលនេះហើយទើបមន្ត្រីរាជការតូចតាចទាំងអស់ជំរាបទៅលោករដ្ឋមន្ត្រី ច័ន្ទ សារុន ឱ្យដេកយកជើងគងថ្ងាសពិចារណាថា បើលោករដ្ឋមន្ត្រីមានគំនិតអាត្មានិយម បក្ខពួកនិយម ដូចក្តីមន្ទិលសង្ស័យខាងលើមែននោះ, លោករដ្ឋមន្ត្រីមិនចាំបាច់ខិតខំរៀបចំការប្រឡងធ្វើអ្វីទេ ពោលគឺធ្វើសេចក្តីប្រកាសឱ្យបុគ្គលណាដែលលោករដ្ឋមន្ត្រីចង់ឱ្យជាប់នោះបានប្តូរក្របខ័ណ្ឌជាស្វ័យប្រវត្តិតែម្តងទៅ។

ព្រោះអ្វី ? ព្រោះបើមានការរៀបចំប្រឡងហើយ បែរជាមិនព្រមប្រកាសលទ្ធផលដូច្នេះ តើការប្រឡងនេះវាមានន័យស្អីទៅ ? តើលោករដ្ឋមន្ត្រីយល់អំពីទឹកចិត្តមន្ត្រីរាជការតូចតាចដែរ ឬក៏អត់ ?

លិខិតបានបញ្ជាក់ច្បាស់ថា មន្ត្រីរាជការតូចតាចដែលសុទ្ធតែមានអតីតភាពការងារជាង ១០ឆ្នាំមកហើយ ។ដូច្នេះពួកគេមានគុណសម្បត្តិគ្រប់គ្រាន់ដែលមិនគួរលោករដ្ឋមន្ត្រី ច័ន្ទ សារុន មើលរំលងយ៉ាងអគតិបែបនេះឡើយ។

ជាងនេះទៀត លិខិតបានសំណូមពរយ៉ាងម៉ឺងម៉ាត់ទៅរដ្ឋាភិបាលសព្វថ្ងៃមេត្តាគិតគូរកែសម្រួលអនុក្រឹត្យផ្សេងៗដើម្បីឱ្យមន្ត្រីរាជការដែលមានអតីតភាពការងារជាង១០ឆ្នាំហើយមានសញ្ញាប័ត្របរិញ្ញាប័ត្រនោះបានប្តូរក្របខណ្ឌពី "ខទៅក" ផង។ ព្រោះបើរំពឹងលើការប្រឡង គឺពិតជាមិនអាចទទួលបាននូវភាពយុត្តិធម៌ត្រឹមត្រូវនោះទេ។

"ខ្មែរម្ចាស់ស្រុក" យល់ថាអ្វីៗដែលលោក ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានធ្វើកន្លងមកនោះគួរតែបញ្ចប់ជាអហោសិកម្មទៅ។ ព្រោះធនធានមនុស្សពិតប្រាកដមិនមែនសំដៅទៅលើមន្ត្រីដែលមានតួនាទីធំៗស្រាប់នោះទេ សំខាន់គឺមន្ត្រីរាជការតូចតាចនេះហើយដែលជាជន្ទល់យ៉ាងរឹងមាំសម្រាប់ទ្រទ្រង់ក្រសួង។

កន្លងមកមានអំពើអយុត្តិធម៌ច្រើនណាស់ដែលថ្នាក់ដឹកនាំក្រសួងកសិកម្មបានធ្វើចំពោះមន្ត្រីថ្នាក់ក្រោមដើម្បីតែបក្ខពួក និងខ្សែស្រឡាយរបស់ខ្លួននោះ។ ចំណែកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឯណោះវិញ គឺចាំតែស៊ីញ៉េប្រថាប់ត្រាបំពេញមុខឱ្យមន្ត្រីក្រោមឱវាទផ្ទាល់តែប៉ុណ្ណោះ ដោយពុំបានគិតទៅដល់ការធ្វើពលិកម្មសព្វបែបយ៉ាងរបស់មន្ត្រីរាជការតូចតាចឡើយ។

ឥឡូវនេះធ្លាយរឿងអាស្រូវបែបនេះទៅហើយ តើនាយករដ្ឋមន្ត្រីត្រូវដោះស្រាយដោយរបៀបណា?ឬមួយទុកឱ្យលោករដ្ឋមន្ត្រីច័ន្ទ សារុន ជិះសេះលែងដៃតទៅទៀត ?

យើងគួរបញ្ជាក់ផងដែរថា លោករដ្ឋមន្ត្រីក្រសួងកសិកម្មដុះស្លែម្នាក់នេះពុំមានសមត្ថភាពអ្វីលើសពីសមត្ថភាពមន្ត្រីតូចតាចក្រោមឱវាទខ្លួននោះទេ។

ជាក់ស្តែងគ្រាន់តែបញ្ហាការកាប់ឈើ, ដឹកជញ្ជូនឈើខុសច្បាប់ដែលកំពុងកើតមានឡើងទាំងយប់ទាំងថ្ងៃ ក៏លោករដ្ឋមន្ត្រីមិនអាចទប់ស្កាត់បានផង តើលោក ច័ន្ទ សារុន ពូកែស្អី?

ម្យ៉ាងទៀតការកាប់ឈើរំលាយព្រៃដើម្បីទន្ទ្រានរានយកដីទៅធ្វើជាកម្មសិទ្ធិឯកជន

តទៅទំព័រ៣ ខ

តមកពីទំព័រ១ ខ

អ៊ីតែ២នៅរដ្ឋសភា ។

ប៉ុន្តែព្រះអង្គ បានក្លាយជាអ្នកមានបាងឆេង មួយដង្ហើមចង្រិត នៅពេលទ្រង់បានជួបជាមួយលោកហ៊ុន សែន តាមទូរស័ព្ទ, ហើយលោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានស្នើឱ្យព្រះអង្គផ្តាច់ខ្លួនពីលោក សម រង្ស៊ី ដែលប្រឆាំងនឹងលទ្ធផលបោះឆ្នោត ដែលពោរពេញទៅដោយភាពមិនប្រក្រតី ។

ភាពមានបាងឆេង នៅមិនទាន់ច្បាស់លាស់នេះ បានធ្វើឱ្យសម្តេចក្រុមព្រះ ផុសចេញនូវមហិច្ឆតាលោភលន់ភ្លាមៗ គឺសុំតំណែងត្រង់ៗ ពីលោកហ៊ុន សែន ដោយមិនខ្មាសអៀន ធ្វើឱ្យលោកហ៊ុន សែន ខឹង គឺមិនលើកទូរស័ព្ទព្រះអង្គ និងមិនចង់និយាយ ជាមួយទ្រង់ឡើយ ពេលព្រះអង្គជូនកាដូគាត់តាមរយៈ នៃការទទួលស្គាល់លទ្ធផលបោះឆ្នោតរួចហើយ ។ ជាមួយគ្នានោះ ឮថាសម្តេចក្រុមព្រះ សុំតំណែងរដ្ឋមន្ត្រីពីលោកនាយករដ្ឋមន្ត្រីហ៊ុន សែន មួយចំនួនដូចជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ព្រមទាំងតំណែងខេត្ត ក្រុងផងដែរ ។

ជាមួយគ្នានោះ ក៏មានព័ត៌មានថា មន្ត្រីឡេមឡឺម ដែលធ្លាប់បង្វិលព្រះអង្គ ឱ្យវង្វេងវង្វាន់ភ្លេចការងារ ដូចលោក សៅ រ៉ានី នោះ ក៏ចង់បានតួនាទីអគ្គស្នងការរង នគរបាលជាតិដែរ ជាពិសេសចង់បានផ្កាយ៣ដាក់លើស្មាដូចមុនទៀត ។

ដោយសារតែមហិច្ឆតា មិនចេះខ្មាសអៀននេះ បានធ្វើឱ្យលោកហ៊ុន សែន ឈប់និយាយរក ហើយថែមទាំងលោកហ៊ុន សែន ស្នើឱ្យដកតំណែង មន្ត្រីដែលស្រឡាញ់ ព្រះអង្គជ្រុលដូចជាលោកមុត ចន្ថា ទៀតផង ។ ដើម្បីបន្ទន់ចិត្តលោកហ៊ុន សែន និងចង់ឱ្យលោកហ៊ុន សែន លើកលែងទោសឱ្យបានឆាប់នោះ សម្តេចក្រុមព្រះយល់ព្រមធ្វើតាម លោកហ៊ុន សែន ទាំងអស់គឺបានដកលោក មុត ចន្ថា ពីអ្នកនាំពាក្យតាមសំណើទៀត ។

អ្នកដែលស្និទ្ធ នឹងសម្តេចក្រុមព្រះបាននិយាយថា ឥឡូវព្រះអង្គ កំពុងស្ថិតនៅក្នុងភាពទ័លច្រកដដែល គឺអ្វីៗបានជូនលោកហ៊ុន សែន អស់ហើយ។ មន្ត្រីដដែល បានឱ្យដឹងទៀតថាលោកហ៊ុន សែន ចង់ឱ្យព្រះអង្គ វិលទៅដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិចវិញ ប៉ុន្តែមិនអាចធ្វើអ្វីដោយអត្តនោម័ត ដូចពេលមុនទេ ។ ប្រភពបានបន្តថា សម្តេចក្រុមព្រះអាចនឹងវិលត្រឡប់ ទៅដឹកនាំហ្វ៊ុនស៊ិនប៉ិចវិញ,ហើយអាចស្នើតំណែងនៅក្នុងរដ្ឋាភិបាលបានខ្លះ បើព្រះអង្គសព្វព្រះទ័យធ្វើអន់លន់តួជាមួយលោកញ៉ឹក ប៊ុនឆៃ ។ តំណែងដែលលោកហ៊ុន សែន អាចឱ្យទ្រង់ យកទៅលក់បានខ្លះនោះ ដូចជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលរងខេត្ត ក្រុង ព្រមទាំងតំណែងឯកអគ្គរាជទូតផងដែរ ។

មន្ត្រីម្នាក់ នៃគណបក្សហ្វ៊ុនស៊ិនប៉ិចបានឱ្យដឹងថាគណបក្សហ្វ៊ុនស៊ិនប៉ិច បានបញ្ជូនបញ្ជីឈ្មោះគណៈរដ្ឋមន្ត្រី ជូនលោកហ៊ុន សែន ហើយ ប៉ុន្តែនៅមិនទាន់ទទួលបានការឆ្លើយតប ពីលោកហ៊ុន សែនវិញទេ ។ ប្រភពដដែលបានអោយដឹងទៀតថាលោកញ៉ឹក ប៊ុនឆៃ បានស្នើតែងតាំងទីប្រឹក្សា ១៣០នាក់ ដែលជំហានទី១ ចំនួន៣០នាក់ត្រូវលោកហ៊ុន សែនយល់ព្រមទាំងអស់ហើយៗ ដំណាក់កាលពី២ចំនួន១០០នាក់ទៀត, តែលោកហ៊ុន សែន យល់ព្រមតែ៨០នាក់ប៉ុណ្ណោះ ។

អ្នកចាស់ទុំហ្វ៊ុនស៊ិនប៉ិចបាននិយាយថា ព័ត៌មានចុងក្រោយនេះសម្តេចក្រុមព្រះបានទទន់ភ្លន់ច្រើនណាស់ជាមួយលោកហ៊ុន សែន និងគណបក្សហ៊្វុនស៊ិនប៉ិច។ ភាពទន់ជ្រាយរហូតសំរេចទទួលស្គាល់ លទ្ធផលបោះឆ្នោត ដែលពោរពេញដោយភាពមិនប្រក្រតីនេះ ជាថ្នូរនឹងព្រះអង្គ អាចយាងត្រឡប់ចូលស្រុកវិញបាន ។ ប៉ុន្តែលទ្ធផលចុងក្រោយព្រះអង្គបានខកព្រះទ័យយ៉ាងខ្លាំង ដែលអ្វីៗទ្រង់បានជូនលោកហ៊ុន សែន អស់ហើយ, ចំណែកលោកនាយករដ្ឋមន្ត្រីហ៊ុន សែនវិញមិនទាន់ឆ្លើយតបជាវិជ្ជមានទេ ហើយថែមទាំង ទទួលយកសំណើពីលោកហ៊ុន សែន ដកតំណែងមន្ត្រីដែលស្មោះត្រង់បំផុត ពីតួនាទីទៀតផង ។

ការសំរេចព្រះទ័យ នាពេលចុងក្រោយ របស់សម្តេចក្រុមព្រះដែលយល់ព្រមដកតំណែងមន្ត្រីល្អៗតាមការស្នើសុំ របស់លោកហ៊ុន សែន នេះ បានធ្វើឱ្យព្រះអង្គ បាត់បង់អ្នកស្មោះត្រង់ និងអ្នកគាំទ្រថែមទៀត នៅពេលដែលព្រះអង្គនៅសល់អ្នកគាំទ្រ និងអ្នកស្មោះត្រង់តិចតួចបំផុតនោះ ។

ចុងក្រោយនេះ លោកហ៊ុន សែន ដាក់លក្ខខណ្ឌអោយព្រះអង្គវិលត្រឡប់ មកដឹកនាំហ៊្វុនស៊ិនប៉ិចវិញ ដែលមិនសូវមានអំណាចដូចមុន ជាថ្នូរនឹងបានចូលស្រុកផង និងបានតំណែងខ្លះគ្រាន់លក់ ដូចទម្លាប់របស់ព្រះអង្គ នៅក្រោយពេលបោះឆ្នោតមុនៗដែរ ។

អ្នកចាស់ទុំហ៊្វុនស៊ិនប៉ិចបានទស្សន៍ទាយទុកជាមុនថា ព្រះអង្គម្ចាស់រណឫទ្ធិ នឹងសុខចិត្តធ្វើអន់ជាមួយលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ហើយ នឹងធ្វើអន់ជាមួយលោកញ៉ឹក ប៊ុនឆៃទៀត ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន បើទោះបីជាផលប្រយោជន៍នោះត្រូវអ្នកគាំទ្រ និងអ្នកស្មោះត្រង់ សើចចំអកឱ្យយ៉ាងណាក៏ដោយ ៕

តមកពីទំព័រ១ ន

លោកដោយផ្ទាល់ដល់ស្រុកយួនតែម្តង។

គម្រោងការលោក សុន ឆ័យ ទៅសួរសុខទុក្ខលោក ទឹម សាខន នៅដើមខែតុលាខាងមុខនេះបន្ទាប់ពីមានព័ត៌មានថា "លោក ទឹម សាខន កំពុងតែជាប់ឃុំក្នុងផ្ទះនៅខេត្តមាត់ជ្រូកប្រទេសយួននៅឡើយទេ ទោះបីជាលោកត្រូវបានអាជ្ញាធរយួនដោះលែងពីពន្ធនាគាររួចហើយក៏ដោយ "។

លោកសុនឆ័យអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានមានប្រសាសន៍ថា "ខ្ញុំនឹងធ្វើដំណើរដោយរួមទាំងក្រុមគ្រួសារលោក ទឹម សាខន ផង មានឪពុកលោកជាដើមទៅសួរសុខទុក្ខលោកដោយផ្ទាល់ "។

អ្នកតំណាងរាស្ត្រដែលមានថ្វីមាត់ឆ្នើមរូបនេះបានបញ្ជាក់ច្បាស់ថា "យើងធ្វើបែបនេះមិនមែនក្នុងនាមគណបក្សស្អីទេ គឺធ្វើឡើងក្នុងនាមជាអ្នកតំណាងរាស្ត្រម្នាក់ដែលទទួលការស្នើសុំពីប្រជាពលរដ្ឋឱ្យជួយដើម្បីទៅពិនិត្យមើលថា តើប្រជាពលរដ្ឋរបស់ខ្ញុំហ្នឹងមានទទួលរងនូវការគាបសង្កត់ដូចការចោទប្រកាន់ដែរ ឬក៏យ៉ាងណា " ?

លោកសុន ឆ័យ បានឱ្យដឹងទៀតថា លោកបានដាក់លិខិតស្នើសុំជាផ្លូវការទៅស្ថានទូតយួនប្រចាំកម្ពុជាកាលពីថ្ងៃទី៨ ខែកញ្ញា កន្លងទៅនេះ។ ប៉ុន្តែខាងស្ថានទូតយួនមិនទាន់បានឆ្លើយតបជាផ្លូវការទៅនឹងការស្នើសុំរបស់លោកនៅឡើយទេ។

យ៉ាងណាក៏ដោយក៏អ្នកនាំពាក្យស្ថានទូតយួនឈ្មោះទ្រិញ បាកឹម បាននិយាយតាមរបៀបរៀបជើងព្រួលទុកជាមុនថា ការធ្វើដំណើររបស់លោក សុន ឆ័យ នោះអាចនឹងប្រព្រឹត្តទៅបានលុះត្រាណាតែមានការអនុញ្ញាតត្រឹមត្រូវជាមុនសិន។

ទ្រិញ បាកឹម បានបញ្ជាក់បន្ថែមទៀតថា លោក ទឹម សាខន បានក្លាយជាប្រជាពលរដ្ឋធម្មតានៅក្នុងប្រទេសវៀតណាមទៅហើយ ។ដូច្នេះលោក ទឹម សាខន នឹងពុំមានឧបសគ្គអ្វីទេក្នុងការទំនាក់ទំនងជាមួយក្រុមគ្រួសារឬសាច់ញាតិនោះ។

ប៉ុន្តែលោក អាង ច័ន្ទរិទ្ធ ប្រធានអង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្សបានបញ្ចេញប្រតិកម្មថា "លោក ទឹម សាខន កំពុងឃុំខ្លួននៅក្នុងផ្ទះនៅឯខេត្តមាត់ជ្រូកប្រទេសយួន និងមានជំងឺថែមទៀតផង "។

ទាក់ទិននឹងការរង់ចាំចម្លើយតបជាផ្លូវការពីស្ថានទូតយួនរបស់អ្នកតំណាងរាស្ត្រ សុន ឆ័យ នេះដែរ សហគមន៍ខ្មែរកម្ពុជាក្រោមដែលដឹកនាំដោយលោក ថាច់ សេដ្ឋា ក៏ដូចជាអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួនទៀតកំពុងតែរង់ចាំទទួលចម្លើយពីស្ថានទូតយួនប្រចាំក្រុងភ្នំពេញដើម្បីបានទៅសួរសុខទុក្ខលោក ទឹម សាខន ដែលកំពុងមានជំងឺ ជាទម្ងន់ និងកំពុងតែរស់នៅដោយគ្មានសេរីភាពពិតប្រាកដនៅឯខេត្តមាត់ជ្រូកប្រទេសយួន។

អង្គការសមាគមខ្មែរកម្ពុជាក្រោមដែលរួមមានទាំងសហគមន៍ខ្មែរកម្ពុជាក្រោមរបស់លោក ថាច់ សេដ្ឋា ផងនោះបានសរសេរលិខិតមួយច្បាប់ផ្ញើទៅស្ថានទូតយួនកាលពីចុងខែសីហា ដោយបានស្នើសុំការអនុញ្ញាតឱ្យពួកគេបានទៅជួបលោក ទឹម សាខន អតីតចៅអធិការវត្តភ្នំដិនខាងជើង។ ហើយបើតាមការលេចឮព័ត៌មានមកនោះ គឺលោក ទឹម សាខន កំពុងមានជំងឺ និងត្រូវគេឃុំខ្លួនលោកនៅក្នុងផ្ទះទៀតផង។

លិខិតនោះបានស្នើសុំអនុញ្ញាតឱ្យគណៈប្រតិភូអង្គការសមាគមខ្មែរកម្ពុជាក្រោមជួបលោកទឹមសាខន ដើម្បីបញ្ជាក់ការពិតឱ្យបានច្បាស់ ជៀសវាងការយល់ច្រឡំចំពោះទង្វើរបស់អាជ្ញាធរយួនកុម្មុយនីស្តតទៅទៀត។

យ៉ាងណាក៏ដោយ លោក ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានថ្លែងថា លោកកំពុងរង់ចាំការឆ្លើយតបពីស្ថានទូតយួន ព្រោះរហូតមកដល់ពេលនេះពុំទាន់មានចម្លើយគួរឱ្យទុកចិត្តណាមួយពីស្ថានទូតយួននៅឡើយទេ។

លោក ថាច់ សេដ្ឋា បានមានប្រសាសន៍ថា "ប្រសិនបើពុំមានការសម្ងាត់អ្វីពីស្ថានភាពរស់នៅរបស់លោក ទឹម សាខន ទេ គួរតែស្ថានទូតយួនអនុញ្ញាតឱ្យពួកយើងទៅជួបសួរសុខទុក្ខលោក ទឹម សាខន ដោយផ្ទាល់ផង "។

មន្ត្រីអង្គការខ្មែរកម្ពុជាក្រោមមួយរូបទៀតបានលើកឡើងថា យើងមានការព្រួយបារម្ភពីសុខភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់លោកទឹមសាខនណាស់។ សំខាន់គឺយើងចង់ដឹងពីប្រវត្តិនៃការផ្សឹកនិងការដាក់ពន្ធនាគារលោកតែម្តង ព្រោះសំណើដែលយើងបានស្នើកាលពីមុនមកនោះ មិនទាន់បានទទួលនូវការឆ្លើយតបសោះ។

ប៉ុន្តែបើសម្រាប់អ្នកនាំពាក្យក្រសួងមហាផ្ទៃឈ្មោះ ខៀវ សុភ័គ វិញ គាត់បាននិយាយតាមរបៀបគ្មានការឈឺឆ្អាលថា "វាពិបាកណាស់ចំពោះអាជ្ញាធរកម្ពុជាក្នុងការធ្វើអន្តរាគមន៍នៅក្នុងករណីនេះ ដោយសារលោក ទឹម សាខន កំពុងស្ថិតនៅក្នុងប្រទេសវៀតណាមហើយគាត់ក៏ជាជនជាតិវៀតណាមដែរ ពិសេសគឺនៅទីនោះមិនអាចមានសញ្ជាតិពីរបានទេ"។

ទោះជាដូច្នេះក្តី ក៏លោក សុន ឆ័យ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីនៅតែមានប្រសាសន៍ដោយទទូចថាលោក និងក្រុមគ្រួសារលោក ទឹម សាខន គ្រោងនឹងធ្វើដំណើរទៅសួរសុខទុក្ខលោកដោយផ្ទាល់នៅឯស្រុកយួននាដើមខែតុលាខាងមុខនេះដែរ។

ម្យ៉ាងទៀតអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួនដែលមានការងារផ្នែកការពារសិទ្ធិមនុស្សនោះ ក៏ទំនងជាកំពុងរង់ចាំមើលការសម្រេចចុងក្រោយរបស់ស្ថានទូតយួនដែរ។ ព្រោះគេជឿថា" ប្រសិនបើពុំមានការសម្ងាត់អ្វីពីស្ថានភាពរស់នៅរបស់លោក ទឹម សាខន ទេ ស្ថានទូតយួនប្រាកដជាអនុញ្ញាតឱ្យមានការទៅជួបសួរសុខទុក្ខលោក ទឹម សាខន ដោយផ្ទាល់ជាមិនខាន "៕

**តមកពីទំព័រ១ គ**

ពេលព្រះមហាក្សត្រ ព្រះបរមនាថ*នរោត្តម សីហមុនី* ព្រះរាជអវត្តមាន នៅក្នុងប្រទេសម្តងៗក៏ដោយ ។

ក្រុមអ្នកតាមដានស្ថានភាពផ្ទៃក្នុងរបស់គណបក្សប្រជាជន បាននិយាយថាការដែលលោក*ជា ស៊ីម* ក្រាញនឿលចង់នៅជាសមាជិកសភានេះ គឺវាមានហេតុផលរបស់គាត់ ព្រោះក្នុងមួយជីវិត របស់ប្រធានគណបក្សគ្មានអំណាចមួយនេះ ចង់ភ្លក្សរសជាតិ នាយករដ្ឋមន្ត្រី របស់លោក*ហ៊ុន សែន* ឱ្យបានម្តង ។

ច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល របស់ប្រទេសខ្មែរ បានកំណត់ច្បាស់ថានាយករដ្ឋមន្ត្រីទាល់តែ ជាសមាជិករដ្ឋសភា ។ ដូច្នេះហើយបានជាលោក*ជា ស៊ីម* មិនព្រមលាលែង ពីសមាជិកសភាជាដាច់ខាត បើទោះបីជាលោក*ហ៊ុន សែន*ខ្លាំងទាំងនៅក្នុងបក្សទាំងនៅក្នុងរដ្ឋាភិបាល យ៉ាងណាក៏ដោយ ក៏មានថ្ងៃបញ្ចប់ដែរ ។ នៅពេលដែលលោក*ហ៊ុន សែន* មានថ្ងៃបញ្ចប់នោះហើយ គឺជាឱកាស ឱ្យលោក*ជា ស៊ីម* បានស្គាល់រសជាតិ នៃការឡើងធ្វើជានាយករដ្ឋមន្ត្រី ។

អ្នកឃ្លាំមើល ផ្ទៃក្នុងរបស់គណបក្សប្រជាជន បានឱ្យដឹងថា នៅពេលបោះឆ្នោតជាតិនាពេលកន្លងមក គណបក្សប្រជាជន បានបង្ហាញអំពីជម្លោះ ដ៏ជ្រាលជ្រៅដែលជម្លោះខ្លះបានឈានទៅដល់ការធ្វើរដ្ឋប្រហារយោធាមិនបានសំរេច ឬការប្រើកម្លាំង របស់លោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* គាបសង្កត់លោក*ជា ស៊ីម* ។

ក្រោយការ បោះឆ្នោតជាតិអាណត្តិទី១ ដែលរៀបចំឡើងដោយអ៊ុនតាក់, រដ្ឋាភិបាលចំរុះមួយបានបង្កើតឡើង ដែលធ្វើឱ្យផ្ទៃក្នុង គណបក្សប្រជាជនជួបនូវភាពស្មុគស្មាញ គឺការប្រជែងតំណែងគ្នា ។ ការបាត់បង់តួនាទីមន្ត្រីជាន់ខ្ពស់ នៅក្នុងភាគីលោក*ជា ស៊ីម* ច្រើនពេកនោះបានធ្វើឱ្យប៉ូលិស ទាហានដែលដឹកនាំដោយ លោក*ស៊ិន សុង* និងលោក*ស៊ិន សេន* ដឹកនាំកម្លាំងយោធា ប៉ូលិស និងប៉េអឹម ធ្វើរដ្ឋប្រហារ ទម្លាក់លោក*ហ៊ុន សែន* នៅយប់ថ្ងៃទី០២ កក្កដា ១៩៩៤ ។ ប៉ុន្តែរដ្ឋប្រហាររលូតនោះ បរាជ័យហើយកម្លាំងលោក*ហ៊ុន សែន* រួមដៃគ្នា ជាមួយសម្តេចក្រុមព្រះ ចាប់មេខ្លោងខាងលោក*ជា ស៊ីម* ជាពិសេសលោក*ស៊ិន សេន* ដាក់ពន្ធនាគារ និងបានធ្វើអោយមេទ័ព គាំទ្រលោក*ជា ស៊ីម* មួយចំនួនទៀតប្រចាំតំបន់ភូមិភាគឦសាន្ត រត់គេចខ្លួនទៅប្រទេសលាវ មួយរយៈទើបវិលត្រឡប់មកវិញ ។

ជម្លោះផ្ទៃក្នុង របស់លោក*ជា ស៊ីម* ជាមួយលោកនាយករដ្ឋមន្ត្រី*ហ៊ុន សែន* ម្តងទៀតនោះ គឺលោក*ហ៊ុន សែន* បញ្ជាឱ្យលោក*ហុក ឡុងឌី* ដឹកនាំកម្លាំងប៉េអឹម ប៉ូលិស រាប់រយនាក់ ទៅឡោមព័ទ្ធភូមិគ្រឹះលោក*ជា ស៊ីម* នៅវិមានរដ្ឋចំការមន កាលពីយប់ថ្ងៃទី១២ ខែកក្កដា ២០០៤ ដែលកាលណោះ លោក*ជា ស៊ីម* មិនព្រមចុះហត្ថលេខាទៅលើធម្មនុញ្ញបន្ថែម ស្តីពីការបង្កើតរដ្ឋសភា និងរដ្ឋាភិបាលកញ្ចប់ ។

ក្រោយៗមកទៀត ជម្លោះរវាងលោក*ហ៊ុន សែន* ជាមួយលោក*ជា ស៊ីម* មិនទាន់បញ្ចប់ទេ ដែលនៅពេលខ្លះ លោក*ហ៊ុន សែន* បានរិះគន់លោក*ជា ស៊ីម* មិនចំពោះឈ្មោះ ដោយប្រើពាក្យពេចន៍ វាយប្រហារលោក*ជា ស៊ីម* យ៉ាងគ្រោតគ្រាត ។ជាងនេះទៅទៀតនោះលោក *ហ៊ុន សែន* បានចូលរួមនៅក្នុងពិធីសម្ពោធសាលាមួយរបស់ឧកញ៉ា*ទ្រី ហេង*ដែលឈ្មោះក្តីលោក*ជា ស៊ីម* រឿងទំនាស់ដីធ្លី នៅជាយក្រុងភ្នំពេញ ដែលការចូលរួម របស់លោក*ហ៊ុន សែន* នោះបានធ្វើឱ្យថ្នាក់ដឹកនាំគណបក្សប្រជាជន យល់ថា ជាការចំអកអោយលោក*ជា ស៊ីម* ។

ទោះបីជា លោក*ជា ស៊ីម* និងលោក នាយករដ្ឋមន្ត្រី*ហ៊ុន សែន* បានបង្ហាញមុខរួមគ្នានៅមុខកញ្ចក់ទូរទស្សន៍ម្តងៗ ថាពួកគេ មិនឈ្លោះគ្នាក៏ដោយ ក៏ទិដ្ឋភាពនោះ មិនអាចបិទបាំង នូវជម្លោះដ៏ស្រួចស្រាល់នេះបានទេ ហើយនៅពេលនេះ បើទោះបីជា គណបក្សប្រជាជន លួចបន្លំសន្លឹកឆ្នោត បាន ៩០អាសនៈ នៅក្នុងសភាយ៉ាងណាក៏ដោយក៏នៅតែមានបញ្ហាជាមួយគ្នាទៀត គឺលោក*ហ៊ុន សែន*បញ្ជាឱ្យបោះឆ្នោតបង្កើតរដ្ឋសភានិងរដ្ឋាភិបាលជាកញ្ចប់ ដែលវិធានការនេះ បង្ហាញថាបើសិនជាការបោះឆ្នោតបង្កើតរដ្ឋសភា ដោយសម្ងាត់នោះ វាមិនបញ្ហាទេ សំរាប់តំណែងប្រធានរដ្ឋសភា ពីព្រោះបេក្ខភាពប្រធានរដ្ឋសភាលោក*ហេង សំរិន* មិនមែនជាមុខសញ្ញា នៃជម្លោះរបស់លោក*ហ៊ុន សែន* និងលោក*ជា ស៊ីម* ។ ប៉ុន្តែនៅពេលបោះឆ្នោត ជ្រើសរើសនាយករដ្ឋមន្ត្រីវិញគឺលោក*ហ៊ុន សែន* ខ្លាចសមាជិកសភាភាគីលោក*ជា ស៊ីម* មិនបោះឆ្នោតគាំទ្រ ។ ម៉្យាងសម្លេងសមាជិកសភា ភាគីលោក*ជា ស៊ីម* និងលោក*ហ៊ុន សែន* ប្រហាក់ប្រហែលគ្នា ដែលចំនួនរបស់ភាគីនីមួយៗ អាចបូកជាមួយសម្លេងគណបក្សផ្សេងពិសេសសមាជិកសភា គណបក្សសមរង្ស៊ីបានគ្រប់ចំនួន៥០%+១ គឺទម្លាក់លោក*ហ៊ុន សែន* បានគ្រប់ពេល ។

នៅពេលដែលទម្លាក់លោក*ហ៊ុន សែន* បានហើយនោះ គឺជាឱកាស របស់លោក*ជា ស៊ីម* ស្គាល់រសជាតិនៃការបានធ្វើជានាយករដ្ឋមន្ត្រី ។ ដូច្នេះហើយបានជាលោក*ជា ស៊ីម* មិនព្រមលាលែង ពីសមាជិកសភាទេ, បើទោះបីជាតំណែងរបស់គាត់សព្វថ្ងៃ ជាប្រធានព្រឹទ្ធសភា និងជាប្រមុខរដ្ឋស្តីទីម្តងៗដែលជាតំណែងខ្ពស់ក៏ដោយ ក៏គាត់មិនលាលែង ពីសមាជិកសភាជាដាច់ខាត ៕

**តមកពីទំព័រ១ ឃ**

រហូតដល់ថ្ងៃទី១៦ ខែកញ្ញា មុនពេលដែលលោកត្រូវចាកចេញទៅកាន់ទីក្រុងហុងកុង ប្រទេសចិន។ នេះបើតាមការឱ្យដឹងពីមន្ត្រីស្ថានទូតអាមេរិកប្រចាំកម្ពុជា។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតអាមេរិកប្រចាំកម្ពុជាកាលពីប៉ុន្មានថ្ងៃមុននេះបានឱ្យដឹងថាក្នុងដំណើរទស្សនកិច្ចរបស់លោក John Negroponte នឹងមានការជួបពិភាក្សាការងារជាមួយមន្ត្រីរដ្ឋាភិបាលសំខាន់ៗ ពិសេសគឺពិភាក្សាជាមួយនាយករដ្ឋមន្ត្រី *ហ៊ុន សែន* និងក្រុមមេដឹកនាំគណបក្សប្រឆាំងផងដែរ។

ក្នុងនោះក៏នឹងមានការជួបជាចាំបាច់ដាច់ដោយឡែកមួយជាមួយក្រុមមន្ត្រីសង្គមស៊ីវិល និងលោក John Negroponte ដើម្បីពិភាក្សាលើបញ្ហាមួយចំនួនដែលទាក់ទិនទៅនឹងដំណើរការប្រជាធិបតេយ្យនៅកម្ពុជាផងដែរ។

មុននេះបន្តិចក្រុមមេដឹកនាំគណបក្សប្រឆាំងបានព្រលយឱ្យដឹងជាមុនថា នឹងយករបាយការណ៍ព្រមទាំងភស្តុតាងទាក់ទិនទៅនឹងភាពមិនប្រក្រតីនៃការបោះឆ្នោតដោយបោកបន្លំនេះជូនលោកឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក John Negroponte ដើម្បីជួយអន្តរាគមន៍ថែមទៀត ទោះបីជាបានប្តឹងយ៉ាងគគ្រឹកគគ្រេងទៅដល់សហគមន៍អឺរ៉ុបរួចហើយក៏ដោយ។

ក្រុមអ្នកតាមដាននានាបានវាយតម្លៃថា ក្នុងដំណើរទស្សនកិច្ចជាផ្លូវការចាប់តាំងពីថ្ងៃនេះរហូតដល់ថ្ងៃទី១៦ខែកញ្ញានោះ លោក Negroponte ប្រាកដជាគ្មានពេលសម្រាកឡើយ ។ហើយបើតាមមន្ត្រីស្ថានទូតអាមេរិកបានឱ្យដឹងថា សហគមន៍ខ្មែរកម្ពុជាក្រោម និងអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួនទៀតក៏បានដាក់លិខិតសុំជួបលោក John Negroponte រួចហើយដែរ។

មេដឹកនាំអង្គការសមាគមខ្មែរកម្ពុជាក្រោមចំនួន៨រូបដែលមជ្ឈដ្ឋានជាទូទៅធ្លាប់បានធ្វើការកត់សម្គាល់ថាជាអ្នកដឹកនាំឆ្នើមៗនោះបានស្នើសុំជួបជាមួយលោក John Negroponte ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកនៅថ្ងៃនេះឬថ្ងៃស្អែកដើម្បីពិភាក្សាអំពីការរំលោភសិទ្ធិខ្មែរក្រោមក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសយួន។

នៅក្នុងលិខិតផ្ញើជូនស្ថានទូតអាមេរិកកាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ លោក*ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានសរសេររៀបរាប់ថា លោកមានបំណងដឹកនាំគណៈប្រតិភូមួយក្រុមដែលមានតំណាងមកពីសមាគមសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម និងសមាគមព្រះពុទ្ធសាសនាខ្មែរកម្ពុជាក្រោមដើម្បីជួបពិភាក្សាជាមួយលោកឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិកខណៈពេលដែលលោកមកបំពេញទស្សនកិច្ចជាផ្លូវការនៅកម្ពុជាក្នុងពេលនេះ។

លោក *ថាច់ សេដ្ឋា* បានបន្តទៀតថា "*គណៈប្រតិភូនឹងដាក់ជូនលោក John Negroponte នូវរបាយការណ៍មួយចំនួនដែលបង្ហាញពីការរំលោភសិទ្ធិមនុស្សយ៉ាងច្រើនលើជនជាតិភាគតិចខ្មែរក្រោមក្នុងប្រទេសវៀតណាម និងក្នុងប្រទេសកម្ពុជា* "។

លោក *ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានថ្លែងឱ្យដឹងថា "*យើងនឹងដាក់ជូនលោក John Negroponte នូវរបាយការណ៍របស់យើង ហើយជម្រុញឱ្យសហរដ្ឋអាមេរិកគាបសង្កត់រដ្ឋាភិបាលឱ្យគោរពសិទ្ធិសេរីភាពរបស់យើងខាងការបញ្ចេញមតិផ្នែកសាសនា និងបញ្ឈប់ការរឹបអូសយកដីធ្លីរបស់យើង* "។

លោក *ចន ចនសុន* អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំកម្ពុជាបាននិយាយកាលពីថ្ងៃព្រហស្បតិ៍កន្លងទៅថា ស្ថានទូតពិតជាបានទទួលលិខិតរបស់គណៈប្រតិភូនេះមែនហើយ។ ប៉ុន្តែមិនទាន់បានសម្រេចពីគម្រោងពេញលេញនៃដំណើរទស្សនកិច្ចរបស់លោក John Negroponte នៅឡើយទេ ដែលដំណើរទស្សនកិច្ចនេះនឹងប្រព្រឹត្តទៅពីថ្ងៃអាទិត្យ ទី១៤ ខែកញ្ញា ដល់ថ្ងៃអង្គារ ទី១៦ ខែកញ្ញា ឆ្នាំ២០០៨។

គួរបញ្ជាក់ថាគ្រាន់តែករណីអតីតព្រះសង្ឃ *ទឹម សាខន* ដែលត្រូវបានអាជ្ញាធរខ្មែរចាប់លោកផ្សឹកយ៉ាងតក់ក្រហល់រួចបញ្ជូនលោកទៅឱ្យតុលាការយួនកាត់ទោសលោកដាក់គុកនៅស្រុកយួននោះ គឺធ្វើឱ្យមានការភ្ញាក់ផ្អើលពេញពិភពលោកទៅហើយ ដោយសារលេចចេញនូវការតវ៉ាយ៉ាងខ្លាំងក្លាបំផុត។

ប៉ុន្តែអាជ្ញាធរយួននៅតែធ្វើមិនដឹងមិនឮដដែល ហើយបន្តឃុំខ្លួនលោក *ទឹម សាខន* ក្នុងផ្ទះរហូតមកដល់សព្វថ្ងៃនេះ ទោះបីជាលោកបានជាប់គុករយៈពេល១ឆ្នាំតាមការកំណត់ដោយតុលាការយួនហើយក៏ដោយ។

មជ្ឈដ្ឋានជាទូទៅរំពឹងថា លោកឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកនឹងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងជាមិនខាន ប្រសិនបើបានមើលនូវរបាយការណ៍របស់អង្គការសមាគមខ្មែរកម្ពុជាក្រោមដែលដាក់ជូនលោកនោះ ។ហើយចំណាត់ការណាមួយនឹងត្រូវកើតយ៉ាងពិតប្រាកដ ព្រោះបញ្ហាខ្មែរកម្ពុជាក្រោមនេះជាបញ្ហាដិតដាមទៅដោយឈាមដែលសហរដ្ឋអាមេរិកមិនអាចមើលរំលងបានជាដាច់ខាត។

ប៉ុន្តែឧត្តមសេនីយ៍ឯក*ខៀវ សុភ័គ*អ្នកនាំពាក្យក្រសួងមហាផ្ទៃត្រូវបាន The Cambodia Daily ដកស្រង់សម្តីលោកយកមកផ្សាយកាលពីថ្ងៃសុក្រ ទី១២ ខែកញ្ញា ថា "*ពាក្យបណ្តឹងរបស់សមាគមខ្មែរក្រោមមួយចំនួនគឺដោយសារតែពួកគេមានការពាក់ព័ន្ធនឹងគណបក្សប្រឆាំងតែប៉ុណ្ណោះ* "៕

**តមកពីទំព័រ២ ង**

នោះ ក៏លោក *ច័ន្ទ សារុន* នៅតែពុំមានវិធានការបង្ក្រាបឱ្យបានម៉ឺងម៉ាត់ដែរ តើលោក *ច័ន្ទ សារុន* ពូកែស្អី ? ដូច្នេះកុំសូវមើលងាយមើលថោកមន្ត្រីរាជការតូចតាចក្រោមបង្គាប់ខ្លួនពេក។

នេះគ្រាន់តែជាដំណឹងល្អមួយសម្រាប់លោក *ហ៊ុន សែន* យកទៅធ្វើការពិចារណាប៉ុណ្ណោះ ដើម្បីធ្វើយ៉ាងណាឱ្យគណៈរដ្ឋមន្ត្រីក្បាលដីកន្ទុយកណ្តុររបស់លោកនៅអាណត្តិទី៤នេះមានតម្លាភាពផង "*កុំនិយមបក្ខពួកសែស្រឡាយរបស់ខ្លួនពេកប្រយ័ត្នបរាជ័យទាំងកណ្តាលទី* "៕

**តមកពីទំព័រ៤ ខ**

នងជាមានតែតួលេខទេឯការពិតនោះអាចមានមិនដល់ពាក់កណ្តាលផង ពីព្រោះនៅពេលដែល ប្រទេសជាតិមានគ្រោះអាសន្នដូចជាចោរសៀមឈ្លានពាន គឺគ្មានកងទ័ពឆ្លើយតបជាមួយគេវិញផងនោះ ។

លោក*យឹម សុវណ្ណ* ប្រធានគណៈកម្មការទី៤ នៃរដ្ឋសភា និងជាមន្ត្រីជាន់ខ្ពស់ របស់គណបក្សសម រង្ស៊ី បានប្រាប់*ខ្មែរម្ចាស់ស្រុក* ពាក់ព័ន្ធនឹងចំនួនកងទ័ពខ្មែរ ដែលលោកទទួលបាន ពីក្រសួងការពារជាតិថា "*មកទល់ពេលនេះ ខ្ញុំមានការងឿងឆ្ងល់ថា ទាហានផ្លូវការមានចំនួនពី១២ ទៅ១៣ ម៉ឺននាក់។ ប៉ុន្តែនៅពេលដែលមានការឈ្លានពានពីបរទេសដូចជានៅទល់ដែន ខាងលិចអ៊ីហ្នឹង, មកដល់ពេលនេះ ហាក់បីដូចជារដ្ឋាភិបាលអល់អែកក្នុងការឆ្លើយតបទៅគេវិញ ដោយការជញ្ជូនកងទ័ព ដាក់យាមល្បាតនោះឃើញថា ហាក់បីដូចជាមានកម្លាំងខ្សោយមែនទែន ។ ដូច្នេះទាហានយើងហ្នឹង មានតែតួលេខទេឯចំនួនពិតប្រាកដនោះ ទំនងជាមិនគ្រប់ចំនួនឡើយ ដោយសារតែអំពើពុករលួយ ទើបទាហានពិតប្រាកដមិនដឹងជានៅកន្លែងណា* " ។

លោក*យឹម សុវណ្ណ* បានបន្តថា ចំពោះប៉ូលិសវិញ លោកក៏ទទួលបានព័ត៌មានថាមានចំនួន៥ម៉ឺននាក់ ។

មន្ត្រីនៃក្រសួងការពារជាតិម្នាក់ អតីតទាហាន KP របស់ភាគីរណសិរ្សជាតិ រំដោះប្រជាពលរដ្ឋខ្មែរលោកតា*សឹន សាន* បានអោយដឹងថា ទាហាននៅតាមកងពល ភូមិភាគ ទាំង៦ នៅកម្ពុជា ព្រមទាំងសឹករងខេត្ត ក្រុងផង មានតែតួលេខប៉ុណ្ណោះ ដែលមេៗស៊ីប្រាក់ខែអស់ហើយ។នៅពេលប្រទេសជាតិត្រូវការ កងពលខ្លះដែលមានចំនួនជិតមួយម៉ឺននាក់ ប្រមូលបានប្រមាណពី៣០០ ទៅ ៤០០នាក់ គឺរាប់បញ្ចូលទាំងអ្នកបើករថយន្ត និងយាមផ្ទះយាមដី អោយមេកងពលផងនោះ ។

ឧត្តមសេនីយ៍ អតីតទាហាន KP ដដែលបានអោយដឹងទៀតថា មិនថាភាគីអតីរដ្ឋកម្ពុជា, អតីតទាហានអានតី (សីហនុនិយម) ទាហាន KP ឬអតីតកូនចៅ លោក*សាក់ ស៊ុតសាខន* ទេ គឺថ្នាក់លើបានបោះបង់ចោលអស់ហើយ ពិសេសពួកទាហានដែលជាទ័ពប្រយុទ្ធនៅសមរភូមិខេត្តបាត់ដំបង, ពោធិសាត់ បន្ទាយមានជ័យ កំពង់ ធំ និងសៀមរាបជាដើមនោះ ត្រូវគេបំភ្លេចចោល ហើយអ្នកខ្លះ ត្រូវអ្នកមានអំណាច អ្នកមានប្រាក់ ប្លន់យកដីធ្លី លំនៅឋានទៀតផង ។

ប៉ុន្តែឧត្តមសេនីយ៍ អតីតទាហាន KP នោះ អះអាងថា ចំពោះមេទ័ពវិញ ពិសេសអតីតមេទាហានរដ្ឋកម្ពុជា, សព្វថ្ងៃនៅមានមុខស្ទើរទាំងអស់ តែភាគច្រើន ដុះក្បាលពោះអស់ហើយ ។ មន្ត្រីយោធារូបនោះបានបន្តទៀតថា ក្រសួងការពារជាតិ រយៈពេលចុងក្រោយនេះខ្វះសព្វខ្វះគ្រប់ គឺខ្វះទាំងរបបប្រេង ប្រាក់ខែបើកអោយកូនទាហានតិចតួច មិនទៀងទាត់គឺវាផ្ទុយពីអ្វីដែលសមាជិករដ្ឋសភាខ្លះនិយាយថាក្រសួងការពារជាតិ មានខ្ទង់ប្រាក់២៦៧ លានដុល្លារក្នុងមួយឆ្នាំៗ ។

បើទោះបីជា ទាហាននៅក្រសួងការពារជាតិ មានការខ្វះខាតខ្លះមែនប៉ុន្តែសំរាប់កងការពារលោក*ហ៊ុន សែន* រាប់ពាន់នាក់មិនខ្វះទេ, ហើយរថពាសដែកនិងរថក្រោះ នៅជុំវិញសុវត្ថិភាពគាត់ ជាង៤០គ្រឿងនោះ ក៏មិនខូចដែរ គឺប្រុងជើងការជានិច្ច សម្រាប់ការសុវត្ថិភាពលោក*ហ៊ុន សែន* ម្នាក់គត់ ៕

**សេវាទទួលទិញសម្ភារៈចាស់ៗ**

មានទទួលទិញ : ផ្ទះឈើ ផ្ទះថ្ម និងសំណង់អគារចាស់ៗតូច-ធំ គ្រប់ប្រភេទដែលត្រូវការរុះរើ ឬវាយចោល និង សម្ភារៈអេតចាយជាច្រើនមុខទៀតដូចជា : ដែក ស្ពាន់ អាលុយមីញ៉ូម ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនភ្លើង អាគុយ ម៉ូទ័រ ។ល។

-មានសេវាចុះទិញតាមខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា
-មានទទួលទិញក្នុងតម្លៃសមរម្យ
-ចំពោះអ្នកដែលផ្តល់ព័ត៌មានក្នុងការទិញលក់នេះ ក្រុមហ៊ុននឹងផ្តល់កម្រៃជើងសារបន្ថែម

ទំនាក់ទំនងទូរស័ព្ទលេខ : **017 606 125**

**ក្រុមហ៊ុនភាពយន្ត ជនបទ**

**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ ទំនាក់ទំនងតាមទូរស័ព្ទ**

**012 66 44 67**
**015 66 44 67**

ខ្មែរម្ចាស់ស្រុក
Khmer Machas Srok News

ការិយាល័យនិពន្ធ
Tel : 012 969 832 , 012 850 690
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsblog.wordpress.com
ផ្នែកផ្សាយពាណិជ្ជកម្ម
Tel: 012 850 690 , 017 360 678, 015 645 170

សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤
Tel: 012 850 690 / 017 360 678 , Fax: 023 987 411

តមកពីទំព័រ១ ស

ត្រឹមតែទ្វេភាគីជាមួយការសន្យាថាយ៉ាងនេះយ៉ាងនោះ រហូតដល់ស្ថានភាពសព្វថ្ងៃនោះ ទើបរដ្ឋាភិបាល *ហ៊ុន សែន* ចាប់ផ្តើមភ្ញាក់កំណើត។ ដោយឃើញស្តែងៗថា អ្វីដែលសៀមបាននិយាយ និងធ្វើ គឺជាការអូសបន្លាយពេលវេលាបំពេញផែនការឈ្លានពានផ្នែកយោធារំលោភយកដីខ្មែរទៀតនោះ ទើបរដ្ឋាភិបាលគណបក្សប្រជាជនឱ្យអ្នកនាំពាក្យរបស់ខ្លួនប្រកាសអំពីការរៀបចំឯកសារទៅវេទិកាអន្តរជាតិ។

រឿងនេះបើគិតពិចារណាឱ្យដល់ទៅនោះ គឺក្រោយពីការបណ្តោយខ្លួនស្តាប់ខ្លួបត្រចៀកនូវពាក្យបញ្ចុះបញ្ចូល របស់រដ្ឋាភិបាលសៀមផង មេទា-ហានសៀមផងថា កុំឱ្យយករឿងបណ្តឹងនេះទៅតវ៉ាដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ រួចសៀមបែរជាបំពានជាច្រើនករណីចូលឈ្លានពានកាន់កាប់ដីខ្មែរបន្ថែមនោះ ទើបរដ្ឋាភិបាល *ហ៊ុន សែន* នឹកឃើញនិយាយអំពីផ្លូវដែលគេបានរំលឹកប្រាប់។

អ្នកនាំពាក្យរបស់រដ្ឋាភិបាល *ហ៊ុន សែន* ដែលជារដ្ឋមន្ត្រីក្រសួងព័ត៌មានលោក *ខៀវ កាញារីទ្ធ* បាននិយាយអំពីការដែល *ហ៊ុន សែន* ឱ្យរៀបចំឯកសារប្រុងជើងការសម្រាប់បន្តការប្តឹងទៅអង្គការសហប្រជាជាតិរកដំណោះស្រាយ។ កាលមុននេះរដ្ឋាភិបាលបាននិយាយអ្វីៗតែតាមពីក្រោយសៀមដើរតាមក្រោយសៀមត្រុកៗ ទោះបីជាដឹងថា សៀមបង្កើតលេសនេះ បង្កឧបសគ្គនោះ ដើម្បីឱ្យមានការអូសបន្លាយពេលវេលាការចរចាដែលពុំឃើញមានចេញលទ្ធផលអ្វី។

តាមពិតទៅគ្រប់មជ្ឈដ្ឋានបានបញ្ចេញមតិឱ្យយោបល់ថា ទាល់តែរដ្ឋាភិបាលកម្ពុជាចេះធ្វើឆ្លាត គិតយកបញ្ហានេះទៅប្តឹងទៅដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យជួយដោះស្រាយបើពុំនោះទេនៅតែចាញ់ល្បិចបោកប្រាស់របស់សៀមអូសបន្លាយពេលឱ្យទាហានសៀមចូលកាន់កាប់ដីខ្មែរ គឺឱ្យកម្ពុជាខាតបង់ទឹកដីនោះហើយ។

នៅចំពោះមុខប្រតិកម្មជួយឈឺឆ្អាលជាទូទៅដែលមតិជាច្រើនបានស្គាល់ក្រយៅពុតខូចរបស់សៀមនោះរដ្ឋាភិបាល *ហ៊ុន សែន* តាមរយៈអ្នកនាំពាក្យរបស់ខ្លួនបានខំនិយាយដោះសាថា រឿងនេះបើបញ្ជូនទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិក៏គេគង់តែរុញឱ្យដោះស្រាយទ្វេភាគីដដែល ដូច្នេះចាំបាច់ទៅប្តឹងអង្គការសហប្រជាជាតិឱ្យគេស្តីឱ្យធ្វើអ្វី។

ឥឡូវនេះអ្វីៗវាចូលតាមរបត់ផ្លូវដែលរដ្ឋាភិបាល *ហ៊ុន សែន* ត្រូវយល់អំពីតម្លៃនៃពេលវេលានិងត្រូវស្គាល់ពុតត្បុតកលល្បិចនៃនយោបាយការទូតនិងវិធីយោធារបស់សៀមក្នុងការបំពានកាន់កាប់ដីខ្មែរតាមបណ្តោយព្រំដែនហើយ។

កាលមុន ទាំង *ហោ ណាំហុង* បាននិយាយអំពីរបស់ដែលហៅថា ការចរចាខ្មែរ-សៀមថ្នាក់ខ្ពស់ប្រព្រឹត្តទៅមុខដូចល្បឿនរូឡែតដំណើរយឺតប្រហែលនឹងដំណើរខ្យង ដើម្បីនិយាយតម្រូវថា ជាការចរចាទ្វេភាគីតាមផ្លូវទូតដើម្បីនឹងបញ្ចៀសការផ្ទុះអាវុធបង្ហូរឈាមឬកុំឱ្យមានសង្គ្រាមរវាងប្រទេសជិតខាងទាំងពីរខ្មែរ-សៀម។

ប៉ុន្តែអ្វីអស់ទាំងនោះគឺជាការចាញ់ប្រៀបល្បិចសៀមទាំងស្រុង ដូចដែល *ហោ ណាំហុង* រដ្ឋមន្ត្រីការបរទេស នៃរដ្ឋាភិបាល *ហ៊ុន សែន* បាននិយាយនៅក្រោយជំនួបថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេសរបស់គាត់ជាមួយ *តេជ ប៊ុនណាក* ថ្ងៃទី១៨-១៩ ខែសីហា។ ក្រោយជំនួបថ្នាក់ខ្ពស់នោះ *ហោ ណាំហុង* តាមបញ្ជារបស់ *ហ៊ុនសែន* បាននិយាយដោយភ្លេចគិតថា ជាការប្រកាសនូវចំណុចខ្សោយខាងវិស័យការទូត និងឥរិយាបថទន់ជ្រាយរបស់រដ្ឋាភិបាលគណបក្សប្រជាជន*ហ៊ុន សែន*។

*ហោ ណាំហុង* ប្រមុខការទូតកម្ពុជាបានប្រកាសប្រាប់អ្នកកាសែតថា កម្ពុជាបើស្ម័គ្រចិត្តឯកឯងមិនបាច់មានសៀមទាមទារតម្រូវអ្វីទេគឺរដ្ឋាភិបាលខ្មែរសុខចិត្តដកបណ្តឹងពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិផង និងជាពិសេសសុខចិត្តដកទាហានខ្មែរជាឯកតោភាគីពីប្រាសាទព្រះវិហារដែលសៀមទទួលស្គាល់ថា ជារបស់ខ្មែរផងនោះឱ្យបានមុនសៀមដកទាហានរបស់ខ្លួនចេញពីដីខ្មែរ។

ប៉ុន្តែអ្វីៗក៏បានប្រព្រឹត្តទៅនៅតាមគន្លងនៃផែនការល្បិចការទូតរបស់សៀមទាំងស្រុង។ ពីព្រោះសៀមប្រើប្រាស់របស់ដែលហៅថា ការចរចាទ្វេភាគីផ្នែកការទូតដើម្បីបិទបាំងនយោបាយឈ្លានពានផ្នែកយោធារបស់ខ្លួនកាន់កាប់ដីខ្មែរ។

ប៉ុន្តែដូចហេតុការណ៍ដ៏ជាក់ស្តែងទាំងទាហានខ្មែរនៅតំបន់តទល់នឹងសៀមផ្ទាល់យល់យ៉ាងច្បាស់នូវភស្តុតាងមិនអាចប្រកែកបាន ហើយដែលមេដឹកនាំរដ្ឋាភិបាល *ហ៊ុន សែន* នៅឯភ្នំពេញក៏មិនអាចនិយាយបង្វែតាមផ្លូវណាផ្សេងនោះ គឺសៀមនៅតែបន្តឈ្លានពានកាន់កាប់ទឹកដីខ្មែរតាមតំបន់ព្រំដែនមួយកន្លែងហើយមួយកន្លែងទៀតឥតឈប់ឈររហូតមកដល់ពេលនេះ។

ចាប់តាំងពីទាហានសៀមឈុតខ្មៅប្រើឈ្មោះថាជាទាហានរបស់ស្តេចសៀមប្រដាប់អាវុធចូលកាន់កាប់ទឹកដីខ្មែរវត្តកែវសិក្ខាគីរីស្វារៈក្នុងតំបន់ប្រាសាទព្រះវិហារដែលទទួលស្គាល់ដោយសាលក្រមតុលាការអន្តរជាតិក្រុងឡាអេឆ្នាំ១៩៦២នោះ ទាហានសៀមក៏បំពានបន្តចូលកាន់កាប់ទឹកដីខ្មែរច្រើនកន្លែងទៀត។ដូចជារយៈពេលក្រោយមកនេះសៀមបានលើកទាហានរបស់ខ្លួនចូលកាន់កាប់ប្រាសាទតាមាន់ធំរបស់កម្ពុជាក្នុងទឹកដីខេត្តឧត្តរមានជ័យ។

ហើយជាបន្តបន្ទាប់សៀមបានលើកទាហានរបស់ខ្លួនចូលឈ្លានពានដីខ្មែរដូចជានៅចម្ងាយច្រើនរយម៉ែត្រទល់នឹងច្រកជាំសាង៉ាំ ព្រមទាំងទឹកដីខ្មែរនៅជប់ត្រឡោក។ ហើយថ្មីៗនេះទាហានសៀមបានចូលមកកាន់កាប់ប្រាសាទតាក្របីនៃទឹកដីខ្មែរ។

ករណីនៃការរំលោភចូលរបស់ទាហានប្រដាប់អាវុធឈុតខ្មៅនៃស្តេចសៀមមកកាន់កាប់ប្រាសាទតាក្របីចំងាយប្រមាណ១៥គីឡូម៉ែត្រពីប្រាសាទតាមាន់ធំនោះគឺជាឧប្បត្តិហេតុតឹកតាងបញ្ជាក់យ៉ាងច្បាស់ថា សៀមមិនកោតញញើត និងមិនត្រូវការស្តាប់ការពិភាក្សាគ្នារវាងខ្មែរសៀមថ្នាក់ណានោះទេ។

ទាល់តែចាញ់បោកសៀមស្រស់ៗបែបនេះហើយ ទើបរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* ធ្វើជាភ្ញាក់ភ្លឺភ្នែកខ្លះ ហើយដឹងខ្លួនថា ល្បិចចរចារបស់សៀមគឺដើម្បីអូសបន្លាយពេលវេលាដើម្បីឱ្យទាហានរបស់សៀមចូលមកកាន់កាប់ទឹកដីខ្មែរ។

មជ្ឈដ្ឋាននានារួមទាំងអង្គការសង្គមស៊ីវិលផងធ្លាប់បានបញ្ចេញប្រតិកម្មផ្តល់អនុសាសន៍ឱ្យរដ្ឋាភិបាលគណបក្សប្រជាជន *ហ៊ុន សែន* កុំបន្តលង់ខ្លួនចាញ់ល្បិចនយោបាយការទូតរបស់សៀម។ ប៉ុន្តែក្រោយពេលដែលសៀមចេះតែបន្តរំលោភឈ្លានពានកម្ពុជាជាហូរហែ ទើបបានរដ្ឋាភិបាល *ហ៊ុន សែន* ព្រមទទួលស្គាល់នូវអ្វីជាកំហុសយុទ្ធសាស្ត្ររបស់ខ្លួនចំពោះមុខសៀម។

ការថ្លែងរបស់តំណាងគណបក្សប្រជាជនថាកម្ពុជានឹងលើកបណ្តឹងតវ៉ាទៅស្ថាប័នអន្តរជាតិនេះ គឺជាជម្រើសនៃការលុបលាងភាពអាម៉ាស់នៃនយោបាយការទូតរបស់ *ហ៊ុន សែន* គណបក្សប្រជាជនតែប៉ុណ្ណោះ។ គឺជាផ្លូវមួយដែល *ហ៊ុន សែន* មិនអាចនឹងជៀសវាងបានក្នុងការរកដំណោះស្រាយជាមួយសៀមជុំវិញបញ្ហានៃការរំលោភបំពានរបស់ទាហានសៀមកាន់កាប់ដីខ្មែរ ថ្វីបើផ្លូវនេះបានធ្វើឱ្យ *ហ៊ុន សែន* បាក់អំណួតព្រោះតែបានលង់ខ្លួនចាញ់ល្បួងនយោបាយការទូតរបស់សៀមនិយាយអំពីការចរចាទ្វេភាគីអស់រយៈពេលពីរខែមកនេះ៕

តមកពីទំព័រ១ ម

ឈុតខ្មៅសៀម ឈ្លានពានទឹកដីខ្មែរជាបន្តបន្ទាប់ នៅតាមព្រំដែនភាគខាងលិច ។

សេចក្តីប្រកាសនោះ បានឱ្យដឹងថា ក្រសួងការពារជាតិជូនដំណឹងដល់យុវជននិស្សិតដែលមានបំណង ចូលធ្វើកងទ័ពជានាយទាហាន និងពលទាហានឱ្យចុះឈ្មោះ ដែលការជ្រើសរើសនេះ ជានាយទាហាន និងពលទាហាន ពោលគឺនាយទាហានរៀនរយៈពេល៤ឆ្នាំ និងពលទាហានធម្មតា ត្រូវរៀនរយៈពេល៦ខែ ។

សេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ជាច្រើនជំនាន់ប៉ុន្តែបានផ្តោតសំខាន់ កងទ័ពជើងគោកជំនាន់ទីមួយ។ លក្ខណៈនៃការជ្រើសរើសនោះ គឺត្រួតពិនិត្យសិក្ខាកាមបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស ហើយក្រសួងសូមជូនដំណឹង ដល់បេក្ខជនជាសិស្សានុសិស្ស និងនិស្សិតទាំងពីរភេទ ដែលបានបញ្ចប់ ការសិក្សាមធ្យមទុតិយភូមិ ឬក៏ថ្នាក់ប្រហាក់ប្រហែល, ហើយមានបំណងស្ម័គ្រចិត្ត ចូលបំរើក្នុងកងយោធពល ខេមរភូមិន្ទ ត្រូវបំពេញបែបបទ តាមវគ្គសិក្សាដូចតទៅ:

-វគ្គសិក្សាសម្រាប់នាយទាហានសកម្ម ជំនាន់ទី១៣ មានរយៈពេល៤ឆ្នាំ

-វគ្គសិក្សា នាយទាហានបឋមទ័ពជើងគោក ជំនាន់ទី១ មានរយៈពេល៤ឆ្នាំ

-វគ្គសិក្សាបន្តវេន ជំនាន់ទី២ មានរយៈពេលសិក្សា៦ខែ។

សេចក្តីប្រកាសព័ត៌មាននេះក៏បានប្រាប់ ដល់អ្នកស្ម័គ្រចិត្តដែលចង់ចូលបំរើកងទ័ព នូវព័ត៌មានលំអិត និងបំពេញទំរង់បែបបទនៅទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋានទល់មុខរោងភាពយន្តលុច្ស និងតាមតំបន់ប្រតិបត្តិការសឹករង ខេត្ត ក្រុងទូទាំងប្រទេស ។ កាលបរិច្ឆេទចាប់ទទួលពាក្យ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ រៀងរាល់ម៉ោងធ្វើការ ។

សេចក្តីប្រកាស ជ្រើសរើសកងទ័ពនេះ គឺស្របពេលដែលប្រទេសជិតខាងខ្មែរ បានឈ្លានពានបូរណភាពទឹកដីនៅតំបន់ភាគខាងលិចពិសេសចោរសៀមបានឈ្លានពាន គ្រប់គ្រងប្រាសាទរបស់ខ្មែរនៅតាមព្រំដែនជាច្រើនកន្លែងដូចជាតំបន់ក្បែរប្រាសាទព្រះវិហារ ប្រាសាទតាមាន់ធំ ប្រាសាទតាក្របី តំបន់ជប់គគីរ និងតំបន់មួយចំនួនទៀត នៅអន្លង់វែង ខេត្តឧត្តរមានជ័យជាដើម ។ ឯកងទ័ពខ្មែរ ដែលមន្ត្រីក្រសួងការពារជាតិអះអាងថា មានប្រមាណពី១២ ទៅ១៣ម៉ឺននាក់នោះទំ

តទៅទំព័រ៣ ម

តមកពីទំព័រ១ ក

**គម្រោងបំណងរបស់រដ្ឋាភិបាលគណបក្សប្រជាជនហ៊ុន សែនក្នុងការបិទការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ហើយប្តូរត្រឡប់ទៅជាទុកឱ្យមានទំនាក់ទំនងជាមួយអង្គការសិទ្ធិមនុស្សពិភពលោកនេះក្នុងកម្រិតទាបជាងមុន។**

**បើស្តាប់ការបកស្រាយរបស់ពួកអ្នកកាន់អំណាចនៅកម្ពុជាដែលខ្លួនឯងមានប្រវត្តិមកត្រួតត្រាប្រទេសដោយសារកម្លាំងយោធាលើកបន្តុបដោយកងទាហានយួនឈ្លានពានកម្ពុជា ហើយដូច្នេះ គឺតាមវិធីនៃការរំលោភបំពានសិទ្ធិមនុស្សនោះ ពួកគេមានមូលហេតុសមទំនងម្យ៉ាងដែរក្នុងការបិទការិយាល័យសិទ្ធិមនុស្សនៅកម្ពុជា។ ប៉ុន្តែអ្វីដែលជាមូលហេតុពិតប្រាកដនៃបំណងចង់បិទការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅស្រុកខ្មែរ ក៏ដោយសារពួកអ្នកកាន់អំណាចនៅស្រុកខ្មែរសព្វថ្ងៃគឺជាក្រុមដែលមានឈ្មោះជាប់ទាក់ទិននឹងការរំលោភសិទ្ធិមនុស្សស្អុយពាសពេញប្រទេស។**

**ធម្មតាមេដឹកនាំប្រទេសទាំងឡាយណាដែលឡើងមកកាន់អំណាចតាមរយៈវិធីសង្គ្រាមបង្ហូរឈាម ឬតាមរយៈរដ្ឋប្រហារ បើទោះបីជាក្រោយៗមកធ្វើជាប្រើវិធីបោះឆ្នោតរបៀបឡប់ឡែបិទបាំងនោះ មេដឹកនាំធុនអស់នោះច្បាស់ណាស់ថា មិនចង់ឮការនិយាយអំពីការមានសកម្មភាពទូលំទូលាយផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនៅប្រទេសដែលខ្លួនត្រួតត្រានោះទេ។ និយាយឱ្យចំ គណបក្សប្រជាជនហ៊ុន សែន ដែលឡើងមកកាន់តំណែងខ្ពស់ហួសពីសមត្ថភាពសព្វថ្ងៃ ហើយ បានធ្វើជាមេចំណែកនៃការបែងចែកអំណាចតំណែងតួនាទី និងការបែងចែកទ្រព្យសម្បត្តិធនធានរបស់ប្រទេសទៅឱ្យគ្នីគ្នា របៀបសព្វថ្ងៃនេះ អ្នកកាន់អំណាចធុននេះប្រាកដច្បាស់ណាស់ថា មិនចង់ឱ្យមានការរីកចំរើនផ្នែកសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជានោះឡើយ។**

**ដូច្នេះហើយទើបបានជាគ្រាន់តែឮថា មានចលនាថ្លែងរិះគន់ខ្លាំងៗ ក៏ដូចជាភស្តុតាងជាក់ស្តែងនៃសម្រែកឈឺចាប់របស់ប្រជារាស្ត្ររងគ្រោះពីការរំលោភផ្នែកសិទ្ធិមនុស្សនានាទាំងការបំពារបំពានផ្នែកសុវត្ថិភាពជីវិត ការរំលោភយក ដីធ្លីផ្ទះសម្បែង ស្រែចំការ រហូតដល់អំពើពុករលួយជាផ្នែកនៃការរំលោភសិទ្ធិមនុស្សដ៏ធំបំផុត គណបក្សប្រជាជន ហ៊ុន សែន ក៏ស្រាប់តែលើកអំពីមូលហេតុចង់បិទការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅស្រុកខ្មែរ។**

**សម្រាប់ប្រជារាស្ត្រខ្មែរប្រសិនបើអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិមិនប្រើសម្ពាធគំនាបឱ្យខ្លាំងលើគណបក្សប្រជាជនសម្រាប់អាណត្តិទី៤ទេនោះ ក្រុមនេះនឹងបិទការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា។ ហើយពេលនោះបញ្ហានៃការរំលោភសិទ្ធិមនុស្សប្រព្រឹត្តិឡើងដូចដែលគេដឹងជាទូទៅគ្រប់គ្នាទាំងក្នុង និងក្រៅប្រទេសថា ជាការប្រព្រឹត្តរបស់ពួកអ្នកមានអំណាចតំណែងខ្ពស់ខាងគណបក្សប្រជាជន និងក្រុមហ៊ុនឈ្មួញទាំងឡាយនោះ ក៏នឹងបង្កើនទំហំបញ្ហាទម្លាក់ទៅលើប្រជារាស្ត្រឱ្យរឹតតែរងគ្រោះថែមទៀត។**

**បញ្ហានៃការរំលោភបំពានយកដីធ្លីរបស់ប្រជារាស្ត្រក្រីក្រដែលកើតមានពាសពេញប្រទេសពុំទាន់ដោះស្រាយបាន។ ហើយអំពើជិះជាន់សង្កត់សង្កិនដោយអំណាចមុខតំណែងរបស់ពួកអ្នកមានអំណាចនិងពួកអ្នកមានលុយក៏នៅតែបន្តកើតមានទៅលើប្រជារាស្ត្រ។ ប្រជារាស្ត្រខ្មែរផ្ទាល់ក៏រស់នៅក្រោមសម្ពាធនៃការគាបសង្កត់សព្វបែបយ៉ាងដើម្បីផែនការនយោបាយពង្រឹងអំណាចរបស់គណបក្សប្រជាជនហ៊ុន សែន។ លើសពីនេះទៅទៀតអំពើពុករលួយនៅតែបន្តរីករាលដាលបំផ្លាញថវិកាជាតិដូច្នេះជាការរំលោភសិទ្ធិមនុស្សមួយផ្នែកយ៉ាងធំទៅហើយ ក៏អំពើនេះនៅតែធ្វើឱ្យប្រជារាស្ត្រខ្មែររងគ្រោះ និងពុំមានដំណោះស្រាយដល់រដ្ឋាភិបាលគណបក្សប្រជាជន ហ៊ុន សែន នោះទេ។**

**គឺអស់ទាំងនេះហើយដែលជាឧទាហរណ៍ខ្លះៗប៉ុណ្ណោះបញ្ជាក់ឱ្យដឹងថា ដរាបណាសហគមន៍ម្ចាស់ជំនួយអន្តរជាតិបណ្តោយឱ្យគណបក្សប្រជាជន ហ៊ុន សែន បិទការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅកម្ពុជាបាននោះ ដរាបនោះប្រជារាស្ត្រខ្មែរគឺជាអ្នករងគ្រោះយំលែងចេញ ហើយរស់រង់ចាំតែថ្ងៃស្លាប់យ៉ាងអយុត្តិធម៌ក្នុងភាពជាជនរងគ្រោះនិងបិទភ្នែកមិនជិតប៉ុណ្ណោះ។**

**ទាំងអង្គការសហប្រជាជាតិ ទាំងម្ចាស់ជំនួយអន្តរជាតិត្រូវតែគិតឱ្យច្បាស់ថា ប្រទេសកម្ពុជាមិនមែនជាកម្មសិទ្ធិកេរ្តិ៍តំណែលរបស់អម្បូរពួកអ្នកកាន់អំណាចមួយក្រុមតូចដែលធ្វើមានបានលើភាពក្រីក្ររបស់ប្រទេសជាតិ បំផ្លាញធនធានសម្បត្តិរបស់ប្រទេស និងលើភាពក្រីក្ររបស់ប្រជារាស្ត្រខ្មែរនោះទេ។ ប៉ុន្តែពួកគេត្រូវតែមានជំហររឹងប៉ឹងម៉ឺងម៉ាត់ច្បាស់លាស់ថា កម្ពុជាគឺជារបស់ប្រជារាស្ត្រខ្មែររួមគ្នាទូទាំងប្រទេស ហើយដូច្នេះក៏គេមិនត្រូវបណ្តោយឱ្យគណបក្សប្រជាជន ហ៊ុន សែន ធ្វើអ្វីៗតាមអំពើចិត្ត ចង់បិទការិយាល័យសិទ្ធិមនុស្សដើម្បីបិទបាំងអំពើរំលោភសិទ្ធិមនុស្សរបស់ពួកខ្លួនលើប្រជារាស្ត្រតាមចិត្តនោះឡើយ។**

**គឺអន្តរជាតិមិនត្រូវបណ្តោយឱ្យមនុស្សមួយក្រុមដែលប្រើល្បិចបោះឆ្នោតបោកបន្លំលួចប្លន់សិទ្ធិរបស់ប្រជារាស្ត្រដើម្បីយកឈ្នះទាំងបំពានគ្មានភាពសុចរិតយុត្តិធម៌នោះ ប្រើឈ្មោះខ្លួនថាជាអ្នកតំណាងរបស់ប្រជារាស្ត្រខ្មែរ ហើយប្រើពាក្យថា អធិបតេយ្យភាពរបស់កម្ពុជាដោយនៅបន្តនយោបាយជិះជាន់សង្កត់សង្កិនខ្មែរឱ្យរស់នៅក្នុងប្រព័ន្ធរបបផ្តាច់ការបែបពួកយោធាផ្តាច់ការភូមានោះទេ៕**